vic roads

បណ្ណព័ត៌មាន

# ភស្តុតាងនៃអត្តសញ្ញាណ

## ភស្តុតាងនៃឯកសារបញ្ជាក់អត្តសញ្ញាណ

លោកអ្នកត្រូវតែផ្តល់ភស្តុតាងនៃអត្តសញ្ញាណរបស់លោកអ្នក នៅពេលដែលលោកអ្នកដាក់ពាក្យនៅ VicRoads (ឧ. ចុះបញ្ជីលេខរថយន្ត ឬប្រលងយកអាជ្ញាបណ្ណបើកបរ)។ បើគ្មានឯកសារត្រឹមត្រូវតែនោះ លោកអ្នកនឹងមិនអាចបំពេញការដាក់ពាក្យបានទេ។ សូមធ្វើការសាកសួរឲ្យបានច្បាស់ថា តើភស្តុតាងជាក់ស្តែងអ្វីខ្លះ ពាក់ព័ន្ធនឹងអត្តសញ្ញាណដែលលោកត្រូវនាំយកមកជាមួយ នៅគ្រាដែលលោកអ្នកធ្វើការណាត់ជួប។

ការផ្តល់ព័ត៌មាន ឬ ឯកសារ ក្លែងបន្លំ និង/ឬបំភាន់ គឺជាបទល្មើសដ៏ធ្ងន់ធ្ងរ ហើយអាចបណ្តាលឲ្យមានការផាកពិន័យ ឬក៏ជាប់ពន្ធនាគារ។

## តើឯកសារបញ្ជាក់អត្តសញ្ញាណប្រភេទណាខ្លះដែលខ្ញុំត្រូវនាំយកមកជាមួយ?

សម្រាប់ការដាក់ពាក្យណាមួយក៏ដោយ គឺលោកអ្នកចាំបាច់ត្រូវផ្តល់៖

- ឯកសារ**មួយ**នៅក្នុងក្រុម A (សូមមើលបញ្ជី)

**និង**

- ឯកសារ**មួយ**នៅក្នុងក្រុម B (សូមមើលបញ្ជីនៅទំព័របន្ទាប់)

យ៉ាងហោចណាស់ក៏មានឯកសារណាមួយនៅក្នុងចំណោមឯកសារទាំងនេះត្រូវតែមានអាសយដ្ឋានស្នាក់នៅបច្ចុប្បន្នរបស់លោកអ្នកនៅក្នុងរដ្ឋវិកថូរៀដែរ។ បើសិនជាគ្មានទេ អ្នកចាំបាច់ត្រូវតែរកឯកសារបន្ថែមទៀត។

## ឯកសារបញ្ជាក់អត្តសញ្ញាណដែលអាចទទួលយកបាន

ឯកសារបញ្ជាក់អត្តសញ្ញាណគឺចាំបាច់ត្រូវតែជាឯកសារដើម។ យើងខ្ញុំមិនទទួលស្គាល់ឯកសារចម្លងទេ។ ឯកសារសរសេរជាភាសាបរទេសត្រូវតែមានភ្ជាប់មកជាមួយនឹងនូវការបកប្រែដោយមានការបញ្ជាក់ត្រឹមត្រូវពីអ្នកបកប្រែ។ អ្នកដាក់ពាក្យដែលមានឯកសារជាភាសាបរទេសត្រូវតែរកអ្នកបកប្រែភាសាឲ្យបកប្រែឯកសារទាំងនោះជាភាសាអង់គ្លេសដោយចំណាយប្រាក់ខ្លួនឯង។

ការបកប្រែឯកសារភាសាបរទេសត្រូវធ្វើឡើងដោយ៖

- អ្នកបកប្រែភាសាដែលមានសញ្ញាបត្រពីស្ថាប័ន NAATI (កម្រិតណាក៏បានដែរ), ឬ
- មន្ត្រីកុងស៊ុលសមស្របនៅក្នុងប្រទេសអូស្ត្រាលី , ឬ
- ការបកប្រែជាផ្លូវការពីប្រទេសដើមកំណើត

## ក្រុមឯកសារ A

- លិខិតឆ្លងដែនអូស្ត្រាលី (បច្ចុប្បន្ន ឬហួសសុពលភាពមិនលើសពី២ឆ្នាំ)
- លិខិតឆ្លងដែនបរទេស (លិខិតឆ្លងដែនដែលហួសសុពលភាពរហូតដល់ទៅ២ឆ្នាំ គឺអាចប្រើការបាន បើសិនជាលោកអ្នកអាចផ្តល់ឯកសារអូស្ត្រាលីសមស្រប ដែលផ្តល់នូវភស្តុតាងមាំទាំអំពីសិទ្ធិស្នាក់នៅជាអចិន្ត្រៃយ៍ មានដូចជាទិដ្ឋាការអចិន្ត្រៃយ៍ ឬទិដ្ឋាការមករស់នៅក្នុងប្រទេសអូស្ត្រាលី ។
- សំបុត្របញ្ជាក់កំណើតនៅអូស្ត្រាលី ឬការចុះបញ្ជីផ្លាស់ប្តូរឈ្មោះ ផ្តល់ឲ្យដោយការិយាល័យអត្រានុកូលដ្ឋាន(Registry of Births, Deaths and Marriages)។ សេចក្តីចម្លងសំបុត្របញ្ជាក់កំណើតនិងសំបុត្របញ្ជាក់ខួបកំណើតគឺគេ**មិន**អាចទទួលយកបានឡើយ។
- ឯកសារបញ្ជាក់ពីអត្តសញ្ញាណចេញដោយការិយាល័យលិខិតឆ្លងដែន(ជាទូទៅផ្តល់ជូនអ្នកធ្វើដំណើរទៅ Norfolk Island)
- ភ្នាក់ងារកងកម្លាំងប៉ូលិសអូស្ត្រាលី បណ្ណអត្តសញ្ញាណមានរូបថត (លើកលែងតែបុគ្គលិកស៊ីវិល)
- អត្តសញ្ញាណបណ្ណកុងស៊ុលមានរូបថត ចេញដោយក្រសួងការបរទេសនិងពាណិជ្ជកម្ម។
- ឯកសារចូលសញ្ជាតិអូស្ត្រាលី ឬឯកសារសម្រាប់ធ្វើដំណើរ ទៅអូស្ត្រាលី ឬបណ្ណភស្តុតាងបញ្ជាក់ពីទិដ្ឋាការ ចេញដោយក្រសួងអន្តោប្រវេសន៍ និងសញ្ជាតិ ឬការិយាល័យលិខិតឆ្លងដែន។
- លិខិតអនុញ្ញាត ឬអាជ្ញាបណ្ណបើកបរអូស្ត្រាលីមានរូបថត (អាជ្ញាបណ្ណមានរូបថតមានន័យថាអាជ្ញាបណ្ណអ្នកបើកបរអូស្ត្រាលីដោយមានរូបថត ឬលិខិតអនុញ្ញាតសម្រាប់អ្នករៀបបើកបរដោយមានរូបថត ដែលមានសុពលភាព ឬហួសសុពលភាព ដែលមិនលើសពី២ឆ្នាំឡើយ ឬអាជ្ញាបណ្ណប្រតិបត្តិការនាវារដ្ឋវិចថូរៀ ឬអាជ្ញាបណ្ណប្រើកាំភ្លើងរដ្ឋវិចថូរៀ ដែលមានសុពលភាព ឬហួសសុពលភាព ដែលមិនលើសពី២ឆ្នាំឡើយ)
- បណ្ណរដ្ឋ NSW ដែលមានរូបថត(ចេញដោយRTA NSW ក្រោយពីថ្ងៃទី14 ខែធ្នូ ឆ្នាំ 2005)។

**ឬ**

- រូបថតបច្ចុប្បន្ន ដែលរក្សាទុកដោយ VicRoads

## ក្រុមឯកសារ B

ឯកសារមួយក្នុងចំណោមឯកសារទាំងនេះ៖

- បណ្ណមេឌីឃែរ
- បណ្ណសម្បទានសោធន (Pensioner Concession card)
- បណ្ណក្រសួងអតីតយុទ្ធជន
- បណ្ណសិទ្ធិទទួលដែលមានសុពលភាពចេញដោយរដ្ឋាភិបាល Commonwealth
- អត្តសញ្ញាណបណ្ណសិស្ស
- បណ្ណឥណទាន (credit card) ឬបណ្ណគណនីពីធនាគារ building society ឬ credit union
- អត្តសញ្ញាណបណ្ណបុគ្គលិករាជការថ្នាក់រដ្ឋ ឬសហព័ន្ធដោយមានរូបថត
- ឯកសារភស្តុតាងនៃ Age card, Keypass card
- អត្តសញ្ញាណបណ្ណកងកម្លាំងការពារជាតិដោយមានរូបថត (លើកលែងតែបុគ្គលិកស៊ីវិល)

**ឬ**

ឯកសារមួយក្នុងចំណោមឯកសារទាំងនេះដែលបិតនៅក្នុងពេលថ្មីៗ ឬអាយុមិនហួសពីជាងមួយឆ្នាំ៖

- សៀវភៅ ឬ របាយការណ៍គណនីធនាគារ
- សំបុត្រទារថ្លៃទូរស័ព្ទ ឧស្ម័ន ឬអគ្គិសនី

**ឬ**

ឯកសារមួយក្នុងចំណោមឯកសារបច្ចុប្បន្ន ឬអាយុមិនលើសពី២ឆ្នាំ៖

- បណ្ណចុះឈ្មោះបោះឆ្នោត
- ឯកសារចេញពីការបម្រើក្នុងជួរកងទ័ព
- ឯកសារភស្តុតាងថ្មីៗ នៃបណ្ណជនចាស់ជរា( Age card) ដែលចេញដោយស្ថាប័ន Consumer Affairs Victoria
- អត្តសញ្ញាណបណ្ណថ្មីៗពីអាជ្ញាធរបើកបរក្នុងរដ្ឋវិចថូរៀ ដែលមានរូបថត
- សំបុត្រទារឲ្យបង់ថ្លៃទឹក (water rates)
- សំបុត្រទារឲ្យបង់ថ្លៃពន្ធសាលាក្រុង (council rates)
- សំបុត្រវាយតម្លៃដី

## ភស្តុតាងបញ្ជាក់ពីភាពមានសិទ្ធិរស់នៅក្នុងរដ្ឋវិចថូរៀ

លោកអ្នកនឹងត្រូវការឯកសារ**មួយ**ក្នុងចំណោមឯកសារដូចតទៅនេះ បើសិនជាឯកសារដែលលោកអ្នកមាន **ពុំ**មានបង្ហាញ អាសយដ្ឋានទីលំនៅរបស់លោកអ្នកនៅក្នុងរដ្ឋវិចថូរៀ ឬក៏អាសយដ្ឋាននោះ**ខុស**គ្នាពីអាសយដ្ឋាននៅក្នុងក្រុមឯកសារ A ឬ B

- កិច្ចសន្យាលក់ដូរ កិច្ចសន្យាជួលផ្ទះ ឬឯកសារជួលវត្ថុប្រើប្រាស់ដែលបង្ហាញអាសយដ្ឋានបច្ចុប្បន្នរបស់លោកអ្នក
- លិខិតផ្តល់ដំណឹងថ្មីៗឲ្យធ្វើអាជ្ញាបណ្ណបើកបរឡើងវិញ ឬបង់ថ្លៃលេខរថយន្តឡើងវិញ
- លិខិតវាយតម្លៃពន្ធដារមកពីការិយាល័យពន្ធដារអូស្ត្រាលី(ឆ្នាំហិរញ្ញវត្ថុបច្ចុប្បន្ន ឬឆ្នាំមុន)

បើសិនជាលោកអ្នកនៅមិនអាចបង្ហាញការរស់នៅរបស់លោកអ្នកនៅក្នុងរដ្ឋវិចថូរៀបានទៀត លោកអ្នកត្រូវតែផ្តល់លិខិតចារពីអាជ្ញាកណ្តាលម្នាក់ (referee) ដែលត្រូវតែ៖

- មានការចុះហត្ថលេខាពីអ្នកដែលមានអាជ្ញាបណ្ណបើកបរក្នុងរដ្ឋវិចថូរៀម្នាក់ដែលបានស្គាល់លោកអ្នករយៈពេលយ៉ាងតិច១២ខែហើយ
- មានដាក់ឈ្មោះនិងអាសយដ្ឋានរបស់លោកអ្នក ហើយ
- ឈ្មោះអាជ្ញាកណ្តាល លេខអាជ្ញាបណ្ណបើកបរ និងហត្ថលេខារបស់អាជ្ញាកណ្តាល

លិខិតនេះត្រូវធ្វើនៅលើទម្រង់បែបបទអាជ្ញាបណ្ណបើកបរ (Licence Application form) ហើយចាំបាច់ត្រូវតែធ្វើឡើង ព្រោះវាជាផ្នែកមួយនៃដំណើរការដាក់ពាក្យសុំនេះ។

## ភស្តុតាងនៃការផ្លាស់ប្តូរឈ្មោះ

លោកអ្នកនឹងត្រូវការឯកសារ**មួយ**ក្នុងចំណោមឯកសារដូចតទៅនេះ បើសិនជាឈ្មោះលោកអ្នក**ខុសពី**ឈ្មោះនៅក្នុងក្រុមឯកសារ A ឬ B៖

- សំបុត្រអាពាហ៍ពិពាហ៍ ចេញដោយការិយាល័យអគ្រានុកូលដ្ឋាននៅក្នុងប្រទេសអូស្ត្រាលី(Registrar of Births, Deaths and Marriages in Australia)
- ឯកសារលែងលះគ្នា(ដោយមានបង្ហាញឈ្មោះ ដែលបានប្តូរ)
- ការដូរឈ្មោះតាមរយៈ deed poll (ដែលធ្វើឡើងមុនខែវិច្ឆិកា ឆ្នាំ 1986 នៅក្នុងរដ្ឋវិចថូរៀ)
- លិខិតបញ្ជាក់ពីការផ្លាស់ប្តូរឈ្មោះ(ចេញក្រោយខែវិច្ឆិកា ឆ្នាំ 1986 នៅក្នុងរដ្ឋវិចថូរៀ)

សម្រាប់ព័ត៌មានបន្ថែម សូមបើកមើលវិបសាយថ៍ **vicroads.vic.gov.au** ឬទូរស័ព្ទទៅលេខ៖ **13 11 71** ឬ អញ្ជើញទៅជួបមណ្ឌលសេវាអតិថិជនរបស់ VicRoads ។

ព័ត៌មានដែលផ្តល់ជូននៅក្នុងបណ្ណព័ត៌មាននេះ គឺត្រឹមត្រូវនៅពេលបោះពុម្ពផ្សាយ ហើយខ្លឹមសារនៃព័ត៌មាននេះអាចមានការផ្លាស់ប្តូរ។

VRPIN02900 Evidence of Identity – Khmer Authorised by VicRoads, 60 Denmark Street, Kew, 3101